# សេចក្តីណែនាំសង្ខេប
# ស្តីពី
## កម្មវិធីរៀនតាមរយៈឌីជីថល

ការចូលរៀនតាមរយៈវេទិកាឌីជីថល អាចប្រព្រឹត្តិទៅបានដោយគោរពតាមជំហ៊ានសំខាន់ៗទាំង៥ ដូចខាងក្រោម៖

| | |
|---|---|
| ជំហ៊ានទី១៖ ចុះឈ្មោះចូលរៀន | • ដើម្បីទទួលបានឈ្មោះប្រើប្រាស់ (Username) និងលេខសម្ងាត់ (Password) ដើម្បីចូលប្រើប្រាស់ប្រព័ន្ធ |
| ជំហ៊ានទី២៖ ចូលប្រើប្រាស់ | • តាមរយៈឈ្មោះប្រើប្រាស់ និងលេខសម្ងាត់ ដែលអ្នកកំណត់នៅពេលចុះឈ្មោះចូលរៀន |
| ជំហ៊ានទី៣៖ ជ្រើសមេរៀន | • ចុចជ្រើសរើសចូលរៀនមេរៀនណាមួយដែលអ្នកចង់ស្វែងយល់បន្ថែម |
| ជំហ៊ានទី៤៖ ចូលរៀនមេរៀន | • ចាប់ផ្តើមរៀនមេរៀនដែលលោកអ្នកជ្រើសរើសតាមជំពូកនីមួយៗ (អាន ស្តាប់ មើលវីដេអូ ឬធ្វើលំហាត់សាកល្បងជាដើម) |
| ជំហ៊ានទី៥៖ ធ្វើតេស្តចំណេះដឹង | • ធ្វើលំហាត់ក្រោយរៀនចប់ដើម្បីតេស្តចំណេះដឹងរបស់អ្នក (ធ្វើប៉ុន្មានដងក៏បាន) |

### អំពីវេទិកាឌីជីថល

- កម្មវិធីរៀនតាមរយៈឌីជីថលនេះមានឈ្មោះថាម៉ូដល (Moodle)
- ម៉ូដលអនុញ្ញាតិឱ្យអ្នកចូលរៀនតាមរយៈគេហទំព័រ ក្នុងកុំព្យូទ័រ ទូរស័ព្ទដៃ និងតាប្លែតជាដើម ។
- ក្រៅពីរៀនតាមរយៈគេហទំព័រ ម៉ូដលក៏អាចប្រើប្រាស់បានក្នុងទូរស័ព្ទ ឬតាប្លែត ដែលមានកម្មវិធីប្រតិបត្តិការអេនឌ្រ័យ (Android Google Play Store) ឬ អាយអូអេស (IOS App Store) ជាដើម ។
- ម៉ូដលក្នុងអេនឌ្រ័យ និងអាយអូអេស អនុញ្ញាតិឱ្យអ្នកបន្តរៀនបានទោះគ្មានសេវាអ៊ីនធើណេតក៏ដោយ ។
- ជាទូទៅ អ្នកត្រូវមានអាសយដ្ឋានអ៊ីមែលផ្ទាល់ខ្លួនដើម្បីចុះឈ្មោះចូលរៀនបាន ។ ប៉ុន្តែម៉ូដលត្រូវបានកែសម្រួលដើម្បីឱ្យអ្នកដែលគ្មានអ៊ីមែលអាចចុះឈ្មោះបានដូចគ្នា ។
- មាតិកាមេរៀន ក៏ត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីរ៉ាពីដប្រូ (RapidPro) ដែលមានន័យថាលោកអ្នកអាចប្រើប្រាស់កម្មវិធីតេលេក្រាម (Telegram) ដើម្បីចូលរៀនបានផងដែរ ។

ចូលរៀនតាមម៉ូដល

ចូលរៀនតាមតេលេក្រាម